ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# គោលនយោបាយស្តីពីឱសថ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

ខែសីហា ឆ្នាំ២០១០

ឧបត្ថម្ភដោយ: អង្គការសុខភាពពិភពលោក

# អារម្ភកថា

ការរៀបចំនិងការអនុវត្តន៍គោលនយោបាយស្តីពីឱសថ នៅព្រះរាជាណាចក្រកម្ពុជា គឺជាការសម្រប សម្រួលវិស័យសុខាភិបាល និងជាការឆ្លើយតបទៅតាមការវិវឌ្ឍន៏រីកចម្រើននៃសង្គម សេដ្ឋកិច្ច បច្ចេកវិទ្យា និង នយោបាយរបស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា ។

គោលនយោបាយស្តីពីឱសថលើកដំបូង ត្រូវបានរៀបចំឡើងនៅឆ្នាំ ១៩៩៥ ។ ដើម្បីឱ្យស្របទៅនឹងផែន ការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល និងការអភិវឌ្ឍន៏របស់វិស័យសុខាភិបាលនាពេលបច្ចុប្បន្ន គោលនយោបាយ នេះ ត្រូវបានធ្វើការពិនិត្យឡើងវិញ ។

ចំណុចសំខាន់របស់គោលនយោបាយដែលបានកែសម្រួលនេះ គឺជំរុញនិងគាំទ្រវិស័យឱសថ ឱ្យមានដំណើរ ការល្អ ដូចជាពង្រឹងការអនុវត្តន៏និយ័តកម្មឱសថ ពង្រឹងការគ្រប់គ្រង និងប្រើប្រាស់ឱសថឱ្យបានសមស្របទាំងសេវា រដ្ឋ និងសេវាឯកជន ធ្វើយ៉ាងណាធានាឱ្យប្រជាជន មានលទ្ធភាពទទួលបាននូវឱសថ សម្រាប់ប្រើប្រាស់ប្រកប ដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ។ ឯកសារនេះក៏បានណែនាំឱ្យបង្កើត និងអនុវត្តបទដ្ឋានផ្សេងៗ សម្រាប់ ធ្វើការអប់រំបណ្តុះបណ្តាលការងារឱសថ ចំពោះសេវារដ្ឋ និងសេវាឯកជន ។

ក្រសួងសុខាភិបាល និងធ្វើការបោះពុម្ពផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវឯកសារគោលនយោបាយនេះជូន ដល់អង្គភាពគ្រប់គ្រងឱសថ ទាំងសេវារដ្ឋ និងសេវាឯកជន ព្រមទាំងអង្គភាពពាក់ព័ន្ធ ដើម្បីជាមគ្គុទ្ទេសក៏សំរាប់ តម្រង់ទិសក្នុងការអនុវត្តន៏ការងារឈានទៅទទួលបានលទ្ធផល កាន់តែល្អប្រសើរនាពេលអនាគតដ៏ខ្លីខាងមុខ ។

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណ និងកោតសរសើរ ចំពោះរាល់ការខិតខំប្រឹងប្រែងទាំងឡាយ របស់មន្ត្រីនៃក្រសួងសុខាភិបាល ជាពិសេសមន្ត្រីនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងក៏ដូច ជាអង្គការសុខភាពពិភពលោក ដែលបានជួយផ្តល់នូវគំនិតល្អៗ រួមគ្នាតាក់តែងកែសម្រួលឱ្យសម្រេចបាននូវឯកសារ គោលនយោបាយស្តីពីឱសថថ្មីនេះ ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមាំថាភាគីពាក់ព័ន្ធទាំងអស់ នឹងផ្តល់នូវការឧបត្ថម្ភគាំទ្រ ស្វែងយល់ និងអនុវត្ត តាមគោលនយោបាយដ៏មានសារៈសំខាន់នេះ ក្នុងការបំពេញរាល់សកម្មភាពការងារទាំងអស់ បម្រើដល់វិស័យសុខា ភិបាល ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ម៉ម ប៊ុនហេង

# គោលនយោបាយស្តីពីឱសថ ២០១០

## មាតិកា


I. **សេចក្តីផ្តើម** ---------- ៤

ទស្សនៈវិស័យ ---------- ៥

បេសកកម្ម ---------- ៥

គោលដៅសំខាន់ៗ ---------- ៥

គោលវិធី ---------- ៥

II. **ក្របខ័ណ្ឌគតិយុត្តិ** ---------- ៦

១. បទដ្ឋានគតិយុត្តិ ---------- ៦

២. តួនាទីនៃអង្គភាពគ្រប់គ្រងឱសថ ---------- ៧

៣. កិច្ចការនិយ័តកម្ម ការធានាគុណភាព និងការផ្តល់អាជ្ញាប័ណ្ណ ---------- ៧

III. **ធនធានមនុស្ស** ---------- ៨

IV. **ធនធានហិរញ្ញវត្ថុ** ---------- ៨

V. **ការជ្រើសរើស** ---------- ៨

១. មគ្គុទ្ទេសក៍ព្យាបាល និងបញ្ជីឱសថសារវន្ត ---------- ៩

១.១. គណៈកម្មការជាតិរៀបចំមគ្គុទ្ទេសក៍ព្យាបាល ---------- ៩

១.២. មគ្គុទ្ទេសក៍ព្យាបាល និងការជ្រើសរើសឱសថ ---------- ៩

២. ការប្រើប្រាស់ឱសថនៅក្នុងក្រុមវេជ្ជសាស្ត្របរទេស និងកម្មវិធីជាតិ ---------- ៩

VI. **ការធ្វើលទ្ធកម្ម** ---------- ៩

១. គោលការណ៍ទូទៅស្តីពីការទិញឱសថ និងបរិក្ខារពេទ្យសម្រាប់វិស័យសាធារណៈ ---------- ១០

១.១. ផលិតកម្មក្នុងស្រុក ---------- ១០

១.២. ការផ្តល់ជំនួយ ---------- ១០

២. ការធ្វើលទ្ធកម្មដោយវិស័យឯកជននៅកម្ពុជា ---------- ១០

VII. **ឃ្លាំង និងប្រព័ន្ធនៃការស្តុកឱសថ** ---------- ១១

១. ការគ្រប់គ្រងស្តុក ---------- ១១

២. ការគ្រប់គ្រងកាកសំណល់ផលិតផលសុខាភិបាល ---------- ១១

VIII. **ការចែកចាយឱសថ** ---------- ១២

១. ការចែកចាយ និងការលក់ឱសថ ---------- ១២

IX. **ការធានាគុណភាពឱសថដែលកំពុងចរាចរ** ------------------------------------ ១៣
X. **ការប្រើប្រាស់ឱសថសមស្រប** ------------------------------------ ១៣
១. ការអប់រំ និងការបណ្តុះបណ្តាល ------------------------------------ ១៣
២. ការចេញវេជ្ជបញ្ជា ------------------------------------ ១៣
៣. ការចែកចាយឱសថ ------------------------------------ ១៤
៤. ព័ត៌មានឱសថ ------------------------------------ ១៤
XI. **ឱសថបុរាណ** ------------------------------------ ១៥
XII. **ការផ្សព្វផ្សាយពាណិជ្ជកម្ម និងការលើកកម្ពស់ការយល់ដឹង** ------------------------ ១៥
XIII. **កិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយប្រទេសនានា និងទីភ្នាក់ងារអន្តរជាតិ** ------ ១៥
១. កិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ ------------------------------------ ១៥
២. កិច្ចសហប្រតិបិត្តការបច្ចេកទេស និងការចែករំលែកព័ត៌មាន---------------------------- ១៦
XIV. **ការត្រួតពិនិត្យ និងការវាយតម្លៃ** ------------------------------------ ១៦

# គោលនយោបាយស្តីពីឱសថ

## I. សេចក្តីផ្តើម

គោលនយោបាយជាតិស្តីពីឱសថសម្រាប់ព្រះរាជាណាចក្រកម្ពុជាត្រូវ បានរៀបចំឡើងជាដំបូងនៅឆ្នាំ១៩៩៥ ។ រយៈពេលដប់ប្រាំឆ្នាំបន្ទាប់ពីការបង្កើតគោលនយោបាយដំបូងនេះ អ្វីៗជាច្រើនត្រូវបានផ្លាស់ប្តូរ ។ វាជាការសំខាន់ណាស់ដែលថា គោលនយោបាយស្តីពីឱសថ ជានិច្ចកាលគួរតែស្របជាមួយនឹងផែនការយុទ្ធសាស្ត្រសុខាភិបាល ។

ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យឱសថឆ្នាំ ២០០៥-២០១០ ដែលបានផ្តល់ការណែនាំយ៉ាងល្អិតល្អន់ លើការពង្រឹងវិស័យឱសថ និងមគ្គុទ្ទេសក៍សម្រាប់ការអនុវត្តន៍ល្អក្នុងឱសថស្ថាន ត្រូវបានគាំទ្រដោយក្រសួងសុខាភិបាលនាឆ្នាំ ២០០៦ ។

ផែនការយុទ្ធសាស្ត្រសុខាភិបាលថ្មីមួយ ត្រូវបានបង្កើតឡើងដោយក្រសួងសុខាភិបាលសម្រាប់ឆ្នាំ ២០០៨-២០១៥ ។ គោលនយោបាយមួយដែលបានបង្កើតឡើងដោយមានការយកចិត្តទុកដាក់យ៉ាងណាក៏ដោយ វានឹងគ្មានតម្លៃប្រសិនបើ គោលនយោបាយនោះមិនត្រូវបានយកមកអនុវត្ត ។ ដូច្នេះផែនការយុទ្ធសាស្ត្រលំអិតនឹងត្រូវបានរៀបចំដើម្បីផ្សារភ្ជាប់ជាមួយគោលនយោបាយស្តីពីឱសថដែលបានកែសម្រួល និងដាក់បញ្ចូលនូវយុទ្ធសាស្ត្រ និងផែនការដែលមានរយៈពេលខ្លី មធ្យម និងវែង សម្រាប់សកម្មភាពជាក់លាក់នៅឆ្នាំក្រោយៗទៀត ។

បញ្ហាសមភាពនៃការទទួលបាននូវឱសថដែលមានគុណភាពល្អ សុវត្ថិភាព ប្រសិទ្ធភាព និងការប្រើប្រាស់ឱសថសមស្រប នៅតែជាចំណុចដែលត្រូវយកចិត្តទុកដាក់របស់គោលនយោបាយនេះ ។ គោលនយោបាយស្តីពីឱសថដែលបានកែសម្រួល មានគោលបំណងធានាឱ្យបាននូវការផ្គត់ផ្គង់ឱសថដែលមានគុណភាពល្អ អាចទុកចិត្តបានសម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប និងគាំទ្រផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ ២០០៨-២០១៥ ។

**គោលបំណងទូទៅនៃគោលនយោបាយស្តីពីឱសថគឺធានាឱ្យបាននូវ :**

- **ការទទួលបាន** : ភាពអាចរកបាន និងលទ្ធភាពដែលអាចចំណាយបានទៅលើឱសថសំខាន់ៗប្រកបដោយសមធម៌
- **គុណភាព**: គុណភាព សុវត្ថិភាព និងប្រសិទ្ធភាពរបស់ឱសថ
- **ការប្រើប្រាស់សមស្រប**: លើកកម្ពស់វិធីព្យាបាល និងចំណាយសមស្របក្នុងការប្រើប្រាស់ឱសថ ដោយអ្នកមានវិជ្ជាជីវៈសុខាភិបាល និងអ្នកប្រើប្រាស់ឱសថ ។

គោលនយោបាយស្តីពីឱសថ គឺជាការប្តេជ្ញាចិត្ត និងជាមគ្គុទ្ទេសក៍សម្រាប់អនុវត្ត ។ គោលនយោបាយនេះ ត្រូវគាំទ្រ និងកែសម្រួលទៅតាមផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ ២០០៨-២០១៥ ។ ការអនុវត្តន៍ គោលនយោបាយនេះ គឺជាវិធីដ៏ល្អបំផុត ក្នុងការធានាឱ្យមានការផ្គត់ផ្គង់ឱសថដែលប្រកបដោយគុណភាពអាចទុកចិត្តបាន សម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់ៗរូប ។

អង្គភាពគ្រប់គ្រងឱសថនៃក្រសួងសុខាភិបាលគឺជាទីភ្នាក់ងាររដ្ឋាភិបាល ដែលទទួលខុសត្រូវចំពោះការគ្រប់គ្រងឱសថនៅក្នុងប្រទេសកម្ពុជា និងជាអង្គភាពដែលមានភារកិច្ចក្នុងការសម្របសម្រួល និងត្រួតពិនិត្យការអនុវត្តន៍គោលនយោបាយស្តីពីឱសថនេះ ។ នៅក្នុងអង្គភាពគ្រប់គ្រងឱសថ មានផ្នែកដែលទទួលខុសត្រូវក្នុងការចុះបញ្ជីឱសថ អធិការកិច្ច ការធ្វើនិយ័តកម្ម និងការធ្វើពាណិជ្ជកម្មឱសថគ្រប់មិជ្ឈភាពទាំងអស់ ហើយត្រូវជួយដល់ការអនុវត្តន៍គោលនយោបាយនេះ ។

ការឆ្លើយតបទៅនឹងគោលដៅនៃគោលនយោបាយនេះ ត្រូវធ្វើការតាមដាន និងវាយតម្លៃដោយអង្គភាពគ្រប់គ្រងឱសថ ។ គោលនយោបាយនេះ ត្រូវបានកែសម្រួល និងអនុលោមទៅតាមការកែសម្រួលផែនការយុទ្ធសាស្ត្រសុខាភិបាលនៅពេលមានការចាំបាច់ ។

## ទស្សនៈវិស័យ

ដើម្បីជួយថែទាំ និងលើកកម្ពស់សុខភាពប្រជាពលរដ្ឋគ្រប់រូបនៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើតំបន់ដាច់ស្រយាល និងប្រជាពលរដ្ឋក្រីក្រ តាមរយៈការទទួលបាននូវការប្រើប្រាស់ឱសថសមស្រប ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ។

## បេសកកម្ម

បេសកកម្មនៃគោលនយោបាយស្តីពីឱសថគឺធានាថា ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាអាចរកទិញបាន និងមានលទ្ធភាពចំណាយទៅលើឱសថដែលមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពជានិច្ច នៅទូទាំងប្រព័ន្ធថែទាំសុខភាពជាតិតាមរយៈ:

- ការពង្រឹង ការអនុវត្តន៍និយ័តកម្ម និងមគ្គុទ្ទេសក៍សម្រាប់ផលិតផលឱសថ រួមមាន ការផលិត ការលក់ ការនាំចូល ការនាំចេញនិងការចែកចាយ ។
- ការបង្កើត និងការអនុវត្តន៍បទដ្ឋានសម្រាប់អនុវត្តការបណ្តុះបណ្តាល និងការអប់រំ ។

## គោលដៅសំខាន់ៗ

គោលដៅសំខាន់ៗនៃគោលនយោបាយនេះគឺផ្តល់ការណែនាំសម្រាប់ :

- ការអភិវឌ្ឍន៍ និងដាក់ឱ្យអនុវត្តបទដ្ឋានច្បាប់ស្តីពីការគ្រប់គ្រងឱសថឱ្យបានត្រឹមត្រូវ ដើម្បីធានាការអនុវត្តន៍គោលនយោបាយស្តីពីឱសថឱ្យបានពេញលេញ
- ការបង្កើត និងដាក់ឱ្យអនុវត្តន៍នីតិវិធីត្រួតពិនិត្យគុណភាព និងចុះទិដ្ឋាការ បញ្ជិកាឱសថ ឱ្យកាន់តែល្អប្រសើរ
- ការធានាឱ្យមានការបែងចែកថវិកាចាំបាច់សំរាប់វិស័យសុខាភិបាល និងការអភិវឌ្ឍន៍គោលនយោបាយដែលពាក់ព័ន្ធ នឹងការផ្តល់ហិរញ្ញប្បទាន ដើម្បីរក្សាថវិកាសម្រាប់ទិញឱសថសារវន្ត ព្រមទាំងរក្សាការគ្រប់គ្រងប្រព័ន្ធឱសថសារវន្ត
- ការអភិវឌ្ឍន៍ និងរក្សាឱ្យដំណើរការនូវមន្ត្រីទទួលខុសត្រូវសមស្រប
- ការជ្រើសរើសឱសថសារវន្ត ដោយផ្អែកលើឯកសារយោងដ៏សមស្រប
- ការធ្វើឱ្យប្រសើរឡើងនូវនីតិវិធីលទ្ធកម្មឱសថ
- ពង្រឹងនីតិវិធី និងការអនុវត្តន៍ការងារគ្រប់គ្រងឱសថ
- ពង្រឹងការចែកចាយ និងការរក្សាទុកឱសថ
- ពង្រឹងការលើកកម្ពស់ប្រើប្រាស់ឱសថប្រកបដោយគុណភាពនៅគ្រប់សេវាសុខាភិបាល
- រក្សាការផ្តល់ព័ត៌មាន និងបន្តកម្មវិធីអប់រំ ដើម្បីឱ្យការប្រើប្រាស់ឱសថកាន់តែប្រសើរឡើង
- បង្កើនសមត្ថភាពនៃការគ្រប់គ្រង និងការអនុវត្តន៍ការងារនៅគ្រប់កម្រិតទាំងអស់ ។

## គោលវិធី

គោលវិធីសំខាន់ៗក្នុងការអភិវឌ្ឍន៍ និងការអនុវត្តន៍គោលនយោបាយស្តីពីឱសថ ៖

- បង្កើនភាពជាដៃគូររវាងស្ថាប័នសំខាន់ៗក្នុងរាជរដ្ឋាភិបាលជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍនានា
- បង្កើនការសម្របសម្រួលនៅក្នុងវិស័យសុខាភិបាលៈ ទីភ្នាក់ងារសាធារណៈ ឯកជន អន្តរជាតិ និងដៃគូអភិវឌ្ឍ
- បង្កើនការសហការគ្នាជាមួយខ្សែបណ្តោយកម្មវិធីជាតិ ដើម្បីធានាឱ្យមានការរួមបញ្ចូលជាមួយប្រព័ន្ធជាតិ
- លើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយផ្នែកផ្សេងទៀតរបស់ក្រសួងសុខាភិបាល
- បង្កើនកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយបណ្តាប្រទេសដទៃទៀត និងទីភ្នាក់ងារអន្តរជាតិនានាដូចជា អង្គការសុខភាពពិភពលោក និងដៃគូអភិវឌ្ឍន៍ដទៃទៀត ។

## II. ក្របខ័ណ្ឌគតិយុត្តិ

ដើម្បីអនុញ្ញាតឱ្យមានការប្រតិបត្តិ គោលនយោបាយជាតិស្តីពីឱសថ តាមរយៈការអនុវត្តន៍ច្បាប់ និងនិយ័តកម្មឱ្យបានត្រឹមត្រូវ ។

### ១. បទដ្ឋានគតិយុត្តិ

#### ១.១. បទដ្ឋានច្បាប់

- ត្រូវបន្តណែនាំការគ្រប់គ្រង និងការត្រួតពិនិត្យវិស័យឱសថតាមបទដ្ឋានច្បាប់ដែលពាក់ព័ន្ធ ។ ដើម្បីគាំទ្រដល់ការអនុវត្តន៍គោលនយោបាយ ត្រូវពង្រឹងច្បាប់ដែលមានស្រាប់ និងច្បាប់ស្តីពីការគ្រប់គ្រងឱសថដែលបានធ្វើវិសោធនកម្មរួចហើយ ។
- ត្រូវដាក់ទោសឱ្យបានធ្ងន់ធ្ងរចំពោះការរំលោភច្បាប់ រួមមានការចែកចាយផលិតផលឱសថដែលគ្មានបទដ្ឋានត្រឹមត្រូវ និង ឱសថក្លែងក្លាយ ។
- ច្បាប់គ្រប់គ្រងឱសថត្រូវតែមានភាពស្របគ្នាជាមួយច្បាប់ផ្សេងៗទៀតដែលមានឥទ្ធិពលលើការអនុវត្តន៍គោលនយោបាយស្តីពីឱសថ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងសុខាភិបាល ឬក្រសួង និងស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាល ។

#### ១.២. បទដ្ឋានច្បាប់កម្មសិទ្ធិបញ្ញាដែលពាក់ព័ន្ធនឹងឱសថ

- អនុលោមតាមកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ពាក់ព័ន្ធនឹងបញ្ហាឱសថ ក្រសួង សុខាភិបាលនឹងបង្កើតបទដ្ឋានច្បាប់ផ្សេងៗ ដើម្បីឱ្យប្រជាជនអាចទទួលបាននូវការប្រើប្រាស់ឱសថតាមលទ្ធភាពចំណាយ របស់ខ្លួនសម្រាប់ព្យាបាលជំងឺដែលបង្កឡើងដោយមេរោគអេដស៍ និងឱសថមានតម្លៃថ្លៃដទៃទៀតដែលការពារដោយ ប្រកាសនីយប័ត្រតក្កកម្ម សម្រាប់តម្រូវការចាំបាច់ក្នុងការដោះស្រាយបញ្ហាសុខាភិបាលនៅក្នុងប្រទេសកម្ពុជា។
- រដ្ឋាភិបាលត្រូវទាញយកផលប្រយោជន៍ពីភាពបត់បែន និងកិច្ចការពារដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) សម្រាប់ការលើកកម្ពស់សុខភាពសាធារណៈ និងធានានូវការទទួលបានឱសថសម្រាប់ប្រើប្រាស់ ។ ក្រសួងសុខាភិបាលត្រូវសហការជាមួយក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងយុត្តិធម៌ ព្រមទាំងស្ថាប័នពាក់ព័ន្ធផ្សេងទៀតក្នុងការរៀបចំក្របខ័ណ្ឌគតិយុត្តិដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដើម្បីបង្កើននូវការទទួលបានឱសថសារវន្ត សម្រាប់ប្រើប្រាស់ដោយរួមបញ្ចូលទាំងការផ្តល់អាជ្ញាប័ណ្ណបញ្ហា ការនាំចូលស្របគ្នា និងផលិតកម្មក្នុងស្រុក សម្រាប់ការប្រើប្រាស់ក្នុងវិស័យសាធារណៈ ។

សុខភាពសាធារណៈ និងការទទួលបានឱសថ សម្រាប់ប្រើប្រាស់ត្រូវចាត់ទុកជាអាទិភាពនៅពេល ធ្វើការចុះហត្ថលេខាទ្វេភាគី ឬសន្ធិសញ្ញាអន្តរជាតិ ឬកិច្ចព្រមព្រៀងណាមួយ ។

- ត្រូវមានការសិក្សាឱ្យបានហ្មត់ចត់លើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដើម្បីការពារផលប្រយោជន៍ជាតិទាក់ទងទៅនឹងសុខភាពសាធារណៈ និងធានាដល់ការទទួលបានឱសថសម្រាប់ប្រើប្រាស់ ។ ដោយឡែករាល់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីណាមួយដែលមានសក្ដានុពល ត្រូវមានការត្រួតពិនិត្យយ៉ាងល្អិតល្អន់ ដើម្បីធានាថា ភាពបត់បែនដែលមាននៅក្រោមកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) គឺមិនត្រូវបាន ប៉ះពាល់ឡើយ ។

## ២. តួនាទីនៃអង្គភាពគ្រប់គ្រងឱសថ

- អង្គភាពគ្រប់គ្រងឱសថត្រូវទទួលខុសត្រូវក្នុងការចុះទិដ្ឋាការ បញ្ជិកាឱសថ ការចេញអាជ្ញាប័ណ្ណបើក បិទគ្រឹះស្ថានឱសថ និង ការធ្វើនិយ័តកម្មទៅនឹងពាណិជ្ជកម្មណាមួយដែលពាក់ព័ន្ធនឹងការគ្រប់គ្រងឱសថ ដូចដែលមានចែងក្នុងបទដ្ឋានច្បាប់ ។ អង្គភាពគ្រប់គ្រងឱសថត្រូវពង្រឹងរចនាសម្ព័ន្ធ និងមានអំណាច ដើម្បីអនុវត្តការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព។
- អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតដែលចេញដោយក្រសួងសុខាភិបាល ត្រូវមានបញ្ជាក់ពីល័ក្ខខ័ណ្ឌផ្សេងៗដើម្បីអនុវត្ត។
- គណៈឱសថការីត្រូវពង្រឹងការអនុវត្តនីមុខងាររបស់ខ្លួន ទៅតាមការកំណត់របស់ក្រសួងសុខាភិបាល រួមមានការចុះបញ្ជីឈ្មោះឱសថការី និងត្រួតពិនិត្យការអនុវត្តន៍ការងាររបស់ពួកគេ ក៏ដូចជាការដោះស្រាយបញ្ហាទំនាស់ផលប្រយោជន៍ ។
- ត្រូវរៀបចំតារាងចំណាត់ថ្នាក់ផលិតផលឱសថ ដើម្បីត្រួតពិនិត្យការលក់ និងការផ្គត់ផ្គង់ផលិតផលឱសថដែលត្រូវមានវេជ្ជបញ្ជា ឬឱសថដែលអាចទិញបានដោយមិនចាំបាច់មានវេជ្ជបញ្ជា នៅតាមកម្រិតផ្សេងៗគ្នា ក្នុងវិស័យ សារធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ អង្គភាពគ្រប់គ្រងឱសថត្រូវរៀបចំបោះពុម្ពផ្សាយ និងធ្វើបច្ចុប្បន្នភាពតាមតម្រូវការនូវតារាងចំណាត់ថ្នាក់ផលិតផលឱសថនីមួយៗ ។

## ៣. កិច្ចការនិយ័តកម្ម ការធានាគុណភាព និងការផ្ដល់អាជ្ញាប័ណ្ណ

គ្រឹះស្ថានអាហារ័ណ ឪហារ័ណ (ក្នុងប្រទេស និងអន្តរជាតិ) និងផលិតផលរបស់ពួកគេ ត្រូវតែគោរពតាមបទដ្ឋានច្បាប់ជាតិ និងអន្តរជាតិ មុនពេលដែលពួកគេអាចចុះទិដ្ឋាការ បញ្ជិកាឱសថនៅក្នុងប្រទេសកម្ពុជា ។ ការិយាល័យចុះបញ្ជិកាឱសថ ត្រូវពិភាក្សាជាមួយបណ្ដាគ្រឹះស្ថានផលិតឱសថទាំងឡាយណា ដែលមានបំណងចង់នាំចូលនូវផលិតផលឱសថ បរិក្ខារពេទ្យ មកកាន់ប្រទេសកម្ពុជា ។

- គ្រឹះស្ថានផលិតឱសថទាំងឡាយណាដែលឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌតម្រូវនៃការចុះទិដ្ឋាការ បញ្ជិកាឱសថ មានសិទ្ធិសុំចុះទិដ្ឋាការ បញ្ជិកា ផលិតផលរបស់ខ្លួនបាន ហើយផលិតផលទាំងនោះឆ្លើយតបនឹងស្តង់ដារគុណភាពជាតិ ឬអន្តរជាតិដែលបានបញ្ជាក់ ដោយមន្ទីរពិសោធន៍ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។
- ការិយាល័យទទួលខុសត្រូវរបស់អង្គភាពគ្រប់គ្រងឱសថ ត្រូវទទួលខុសត្រូវក្នុងការចេញអាជ្ញាប័ណ្ណនាំចូលអោយនិតិបុគ្គលណាដែលបានការអនុញ្ញាតក្នុងការ នាំចូលឱសថ និងបរិក្ខារពេទ្យមកកាន់ប្រទេសកម្ពុជា ។
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ត្រូវអនុញ្ញាតឱ្យនាំចូលតែឱសថណាដែលមានអាជ្ញាប័ណ្ណនាំចូលនៅមានសុពលភាពប៉ុណ្ណោះ។
- មន្ត្រីអធិការកិច្ចឱសថ ត្រូវមានទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រីគយ ក្នុងការត្រួតពិនិត្យឱសថទាំងឡាយណា ដែលបាននាំចូលមកក្នុងប្រទេសកម្ពុជា។

### ៣.១. មន្ទីរពិសោធន៍ជាតិសម្រាប់ការត្រួតពិនិត្យគុណភាពឱសថ

- មន្ទីរពិសោធន៍ទទួលស្គាល់ដោយក្រសួងសុខាភិបាល សម្រាប់ការត្រួតពិនិត្យគុណភាពឱសថ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពនៃផលិតផលសុខាភិបាល ។
- មន្ទីរពិសោធន៍ទទួលស្គាល់ដោយក្រសួងសុខាភិបាល សម្រាប់ការត្រួតពិនិត្យគុណភាពឱសថ ត្រូវពង្រឹងបន្ថែម ដើម្បីឈានទៅទទួលបាននូវស្តង់ដារប្រតិបត្តិការ ដែលទទួលស្គាល់ដោយអន្តរជាតិ ។
- អគារ ឧបករណ៍ សម្ភារៈមន្ទីរពិសោធន៍ ត្រូវអភិវឌ្ឍឱ្យទំនើបឡើង ជាមួយគ្នានោះសមត្ថភាពធនធានមនុស្ស សម្រាប់ មន្ទីរពិសោធន៍ ក៏ត្រូវមានការពង្រីកបន្ថែម រក្សាទុក និងធ្វើឱ្យប្រសើរឡើងថែមទៀត ។

## III. ធនធានមនុស្ស

គោលនយោបាយនេះមានគោលបំណងធានាឱ្យមានចំនួនបុគ្គលិកសមស្រប ហើយបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃគោលនយោបាយស្តីពីឱសថ ។

- ផែនការយុទ្ធសាស្ត្រសម្រាប់ការបង្កើន និងការរក្សាធនធានមនុស្សដែលចាំបាច់សម្រាប់ការអនុវត្តន៍គោលនយោបាយស្តីពីឱសថ ត្រូវអភិវឌ្ឍដោយមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយបណ្តាឋានាយកដ្ឋានពាក់ព័ន្ធ ។ ដើម្បីអនុវត្ត គោលនយោបាយនេះបាន ត្រូវមានផែនការសម្រាប់កំណត់ធនធានមនុស្ស ដែលជាយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍក្នុងការ ជ្រើសរើស និងបណ្តុះបណ្តាលបុគ្គលិកនាពេលអនាគត ។
- ក្រសួងសុខាភិបាលត្រូវព្យាយាមកែលំអទស្សនវិស័យអាជីពរបស់បុគ្គលិកផ្នែកឱសថ ហើយត្រូវលើកទឹកចិត្ត និងគាំទ្រក្នុងការទទួលបាននូវកាលានុវត្តន៍ភាព និងវគ្គសិក្សាបង្កើនជំនាញបន្ថែមដល់បុគ្គលិកដែលមានស្រាប់ ដើម្បីធានាតួនាទីរបស់ពួកគេ និងជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍធនធានមនុស្ស ។

## IV. ធនធានហិរញ្ញវត្ថុ

គោលនយោបាយនេះ មានគោលបំណងធានាឱ្យមានការផ្តល់មូលនិធិគ្រប់គ្រាន់សម្រាប់ឱសថសារវន្ត ដែលមានគុណភាពល្អ និងបរិមាណគ្រប់គ្រាន់ក្នុងតម្លៃទាបដែលអាចធ្វើបាន ទៅតាមលទ្ធភាពនៃការផ្តល់ថវិកាសរុបរបស់ក្រសួងសុខាភិបាលក្នុងការអនុវត្តន៍យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីឱសថ ។

តម្រូវការធនធានហិរញ្ញវត្ថុ ត្រូវផ្អែកលើការប៉ាន់ប្រមាណតម្រូវការដោយប្រុងប្រយ័ត្ននូវបរិមាណសរុបនៃឱសថ និងបរិក្ខារពេទ្យ ដោយប្រើទិន្នន័យដែលបានមកពីប្រភពអាចទុកចិត្តបាន និងស្របទៅតាមផែនការយុទ្ធសាស្ត្រក្នុងការអនុវត្តន៍គោលនយោបាយស្តីពីឱសថ ។

## V. ការជ្រើសរើស

គោលនយោបាយនេះមានគោលបំណងក្នុងការជ្រើសរើសផលិតផលឱសថ ដោយអនុលោមទៅតាមបញ្ជីឱសថសារវន្តដូចដែលបានផ្តួចផ្តើមគំនិតដោយអង្គការសុខភាពពិភពលោក (WHO) ។ ឱសថសារវន្ត គឺជាឱសថដែលមានលក្ខណៈសំខាន់ និងចាំបាច់បំផុត ដើម្បីបំពេញតម្រូវការសុខភាពរបស់ប្រជាជនភាគច្រើន ។

១. មគ្គុទ្ទេសក៍ព្យាបាល និងបញ្ជីឱសថសារវន្ត

១.១ គណៈកម្មការជាតិរៀបចំមគ្គុទ្ទេសក៍ព្យាបាល

គណៈកម្មការរៀបចំមគ្គុទ្ទេសក៍ព្យាបាលដែលមានសមាសភាពរួមមាន អ្នកជំនាញឯកទេសផ្សេងៗ ដែលត្រូវពង្រឹង ដើម្បីរៀបចំមគ្គុទ្ទេសក៍ព្យាបាលសម្រាប់គ្រប់ស្ថានភាពជម្ងឺដែលកើតមាននៅក្នុងប្រទេស ។ អនុគណៈកម្មការជំនាញឯកទេស អាចត្រូវបានជ្រើសរើសដើម្បីដោះស្រាយបញ្ហានៅតំបន់ដែលមានជម្ងឺ ។

១.២. មគ្គុទ្ទេសក៍ព្យាបាល និងការជ្រើសរើសឱសថ

- ការជ្រើសរើសឱសថដើម្បីប្រើប្រាស់សម្រាប់ការព្យាបាល ត្រូវផ្អែកទៅលើភាពជាក់ស្តែងនៃសុវត្ថិភាព ប្រសិទ្ធភាព ចំណាយសមស្របក្នុងការប្រើប្រាស់ឱសថ និងគុណប្រយោជន៍នៃការព្យាបាល ។
- ដើម្បីសម្រួលដល់ឯកសារយោង ត្រូវមានការពិនិត្យឡើងវិញនូវមគ្គុទ្ទេសក៍ព្យាបាលដែលមានស្រាប់ និងចងក្រងជាឯកសារសង្ខេប ដែលមានខ្លឹមសារច្បាស់លាស់ដោយគណៈកម្មការមគ្គុទ្ទេសក៍ព្យាបាល ។ ការរួមបញ្ចូលនូវមគ្គុទ្ទេសក៍ព្យាបាល ចំពោះករណីជម្ងឺនិមួយៗសម្រាប់យកទៅប្រើប្រាស់គ្រប់ស្ថានភាពជម្ងឺដែលកើតមាននៅក្នុងប្រទេស ។ ដំណើរការនៃការអភិវឌ្ឍន៍មគ្គុទ្ទេសក៍ព្យាបាល ត្រូវកំណត់អំពីឈ្មោះឱសថដែលត្រូវដាក់បញ្ចូលទៅក្នុងបញ្ជីឱសថសារវន្តជាតិ ។
- មគ្គុទ្ទេសក៍ព្យាបាល និងបញ្ជីឱសថសារវន្ត ត្រូវធ្វើការពិនិត្យឡើងវិញឱ្យបានទៀងទាត់ដើម្បីរក្សាការព្យាបាលជម្ងឺឱ្យបានត្រឹមត្រូវ ។
- ត្រូវបន្តការជ្រើសរើសឱសថដោយផ្អែកលើឈ្មោះហ្សេណេរិក (Generic) ឬឈ្មោះអន្តរជាតិ (INN) ។ ក្រៅពីករណីលើកលែងមួយចំនួននៅថ្នាក់កណ្តាល នៅពេលដែលមានការវិនិច្ឆ័យត្រឹមត្រូវតាមបែបវេជ្ជសាស្ត្រមានតែឱសថ ដែលមាននៅក្នុងបញ្ជីឱសថសារវន្តជាតិតែប៉ុណ្ណោះ ដែលត្រូវយកមកប្រើនៅក្នុងសេវាសាធារណៈ ។ គណៈកម្មការត្រូវកំណត់កម្រិតថ្នាក់ឱសថខុសៗគ្នា ដែលមានទៅតាមថ្នាក់ជាតិ ខេត្ត ស្រុក និង ឃុំ ។

២. ការប្រើប្រាស់ឱសថនៅក្នុងក្រុមវេជ្ជសាស្ត្របរទេស និងកម្មវិធីជាតិ

- ក្រុមវេជ្ជសាស្ត្រ ឬជនបរទេសណាម្នាក់ ដែលមានបំណងសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តន៍កម្មវិធីប្រើប្រាស់ឱសថគឺជាផ្នែកមួយសំខាន់ ដែលត្រូវពិភាក្សាជាមួយអង្គភាពគ្រប់គ្រងឱសថ ដើម្បីទទួលបានកិច្ចព្រមព្រៀងទាក់ទងនឹងការប្រើប្រាស់ឱសថទាំងនោះ ។
- ការជ្រើសរើស និងការប្រើប្រាស់ឱសថគឺជាផ្នែកមួយសំខាន់ ដែលត្រូវធ្វើការពិភាក្សាជាមួយអង្គភាពគ្រប់គ្រងឱសថមុននឹងផ្តល់ការណែនាំលើការប្រើប្រាស់ឱសថទាំងនោះទៅតាមប្រភេទជម្ងឺ ឬតាមកម្មវិធីជាតិ (ឧទាហរណ៍ កម្មវិធី IMCI STI HIV និងកម្មវិធីស្តីអំពីជម្ងឺទឹកនោមផ្អែម) ។

## VI. ការធ្វើលទ្ធកម្ម

គោលនយោបាយនេះមានគោលបំណងធានាថា គុណភាព និងបរិមាណឱសថចាំបាច់ ត្រូវបានធ្វើលទ្ធកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការសុខភាពរបស់ប្រជាពលរដ្ឋ ក្នុងតម្លៃទាបតាមដែលអាចធ្វើបាន ។

## ១. គោលការណ៍ទូទៅស្តីពីការទិញឱសថ និងបរិក្ខារពេទ្យសម្រាប់វិស័យសាធារណៈ

នៅក្នុងវិស័យសាធារណៈ លទ្ធកម្មឱសថត្រូវធ្វើឱ្យមានលក្ខណៈស្របគ្នា និងរួមបញ្ចូលទៅជាប្រព័ន្ធជាតិ ដើម្បីទទួលបាននូវមាត្រដ្ឋានសេដ្ឋកិច្ច និងធានាឱ្យមានការផ្គត់ផ្គង់ឱសថដែលអាចជឿទុកចិត្តបាន ក្នុងការបំពេញតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា ដោយកាត់បន្ថយជាអតិបរមានូវការខ្ជះខ្ជាយ ។

គោលបំណងនៃការទិញឱសថគឺ ការទទួលបាននូវឱសថដែលមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ក្នុងតម្លៃទាបតាមដែលអាចធ្វើបាន។

- នីតិវិធី និងមគ្គុទ្ទេសក៍សម្រាប់លទ្ធកម្មប្រកបដោយប្រសិទ្ធភាពដែលបានធ្វើឱ្យស្របគ្នា ត្រូវធ្វើការពិនិត្យឡើងវិញ និងពង្រឹងបន្ថែមទៀត។
- មានតែឱសថដែលបានចុះទិដ្ឋាការ បញ្ជិកា ឬបានទទួលស្គាល់ដោយក្រសួងសុខាភិបាលប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យធ្វើ លទ្ធកម្ម។
- ត្រូវបន្តធ្វើលទ្ធកម្មឱសថ តាមឈ្មោះហ្សេណេរិក (Generic) ឬឈ្មោះអន្តរជាតិ (INN) ។
- ត្រូវបន្តធ្វើលទ្ធកម្មឱសថដោយយោងទៅតាមបញ្ជីឱសថសារវន្តជាតិ ។

### ១.១. ផលិតកម្មក្នុងស្រុក

- ការធ្វើលទ្ធកម្ម គួរតែផ្តល់លទ្ធភាពឱ្យឱសថដែលផលិតក្នុងស្រុកនូវចំនួនមួយដែលមានកម្រិត។
- ផលិតផលឱសថក្នុងស្រុក ដែលមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ហើយដែលបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋត្រូវបានលើកទឹកចិត្ត ។
- គ្រឹះស្ថានផលិតឱសថត្រូវបានលើកទឹកចិត្ត និងគាំទ្រដើម្បីប្រតិបត្តិតាមល័ក្ខខ័ណ្ឌតម្រូវ រួមមានគោលការណ៍អនុវត្តល្អក្នុងផលិតកម្មឱសថ (GMP) របស់ជាតិ និងរបស់អង្គការសុខភាពពិភពលោក សម្រាប់ការផលិតនូវផលិតផលឱសថ។
- គ្រឹះស្ថានផលិតឱសថត្រូវបានលើកទឹកចិត្តឱ្យផលិត និងនាំចេញផលិតផលឱសថ ដោយគោរពតាមស្តង់ដារអន្តរជាតិ និង អភិវឌ្ឍសមត្ថភាពឈានដល់កម្រិតស្តង់ដារ និងគោរពតាមគម្រោងផែនការផ្តល់វិញ្ញាបនប័ត្ររបស់អង្គការសុខភាព ពិភពលោក ទៅលើគុណភាពផលិតផលឱសថដែលចរាចរនៅក្នុងពាណិជ្ជកម្មអន្តរជាតិ ។

### ១.២. ការផ្តល់ជំនួយ

មគ្គុទ្ទេសក៍ជាតិសម្រាប់ផ្តល់ជំនួយឱសថ នឹងត្រូវបានបង្កើតឡើង ហើយការផ្តល់ជំនួយឱសថក្នុងវិស័យសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវគោរពតាមមគ្គុទ្ទេសក៍ជាតិ ដែលបានអនុម័តដោយក្រសួងសុខាភិបាល។

## ២. ការធ្វើលទ្ធកម្មដោយវិស័យឯកជននៅកម្ពុជា

- ក្រសួងសុខាភិបាល ត្រូវបន្តផ្តល់អាជ្ញាប័ណ្ណនាំចូល ឬលិខិតអនុញ្ញាត ជូនគ្រឹះស្ថានអាហារ័ណ នីហារ័ណឱសថ។
- មានតែឱសថដែលបានចុះបញ្ជិកានៅកម្ពុជាប៉ុណ្ណោះ ដែលត្រូវបន្តការធ្វើលទ្ធកម្ម សម្រាប់លក់ក្នុងវិស័យឯកជន។
- មានតែឱសថដែលគោរពតាមស្តង់ដារគុណភាពជាតិ និងអន្តរជាតិប៉ុណ្ណោះ ដែលត្រូវនាំចូលដោយវិស័យឯកជនសម្រាប់លក់នៅ ក្នុងប្រទេសកម្ពុជា។

## VII. ឃ្លាំង និងប្រព័ន្ធនៃការស្តុកឱសថ

គោលនយោបាយនេះមានគោលបំណង ធានាឱ្យបាននូវ:

- ការរក្សាគុណភាព និងសុវត្ថិភាពឱសថនៅក្នុងឃ្លាំងរបស់វិស័យសាធារណៈ ឯកជន និងស្ថាប័នមិនមែនរដ្ឋាភិបាលចាប់ពីពេលទទួលឱសថចូលទៅក្នុងឃ្លាំងរហូតដល់ពេលចែកចាយទៅឱ្យអ្នកជំងឺ ។ ការបន្តឱ្យមានជាប្រចាំនូវបរិមាណគ្រប់គ្រាន់នៃឱសថសារវន្ត តាមគ្រប់កម្រិតទាំងអស់នៃប្រព័ន្ធសុខាភិបាល តម្រូវឱ្យមានការរក្សាប្រព័ន្ធកត់ត្រា ត្រួតពិនិត្យ របាយការណ៍ នៃការប្រើប្រាស់ឱសថ និងបរិមាណស្តុកឱសថគ្រប់មុខ ឱ្យបានច្បាស់លាស់ ។
- កាត់បន្ថយភាពខ្វះខាតឱ្យនៅកម្រិតអប្បបរមាតាមល័ក្ខខ័ណ្ឌ និងមានប្រសិទ្ធភាពនៃការស្តុកឱសថ ការរក្សាកំណត់ត្រា និងការគ្រប់គ្រងស្តុកឱ្យបានត្រឹមត្រូវ ។ ការកំទេចឱសថ ត្រូវធ្វើឡើងតាមវិធីប្រកបដោយសុវត្ថិភាព និងមិនប៉ះពាល់ដល់បរិស្ថាន ។

### ១. ការគ្រប់គ្រងស្តុក

- ការស្តុក និងការចែកចាយឱសថ បរិក្ខារពេទ្យ ទៅវិស័យសាធារណៈ ត្រូវបន្តការគ្រប់គ្រងពីថ្នាក់ជាតិ ដោយមានមគ្គុទេសក៍ត្រឹមត្រូវមួយ ដែលមានរចនាសម្ព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ។
- ឃ្លាំងស្តុកឱសថ និងគ្រឿងបំពាក់ក្នុងឃ្លាំងនៅថ្នាក់កណ្តាលនិងថ្នាក់ក្រោម ត្រូវមានការវាយតម្លៃ និងរៀបចំឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យមានសុវត្ថិភាពក្នុងការស្តុកផលិតផលឱសថ ឱ្យត្រូវតាមលក្ខខណ្ឌសីតុណ្ហភាព និងសំណើម រហូតដល់ពេលឱសថ និងបរិក្ខារពេទ្យ ផុតកំណត់ប្រើ ។
- ក្រសួងសុខាភិបាល ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពក្នុងការធានាផ្តល់ឱ្យបានគ្រប់គ្រាន់នូវបុគ្គលិក ដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ។
- ត្រូវធ្វើបច្ចុប្បន្នភាពមគ្គុទ្ទេសក៍នៃការគ្រប់គ្រងឱសថ ហើយត្រូវចែកទៅឱ្យប្រព័ន្ធផ្គត់ផ្គង់គ្រប់ថ្នាក់ សម្រាប់ធ្វើការបណ្តុះបណ្តាល និងណែនាំអំពីការងារគ្រប់គ្រង និងស្តុកឱសថ ។
- យោងទៅតាមមគ្គុទេសក៍ទាំងនេះ ត្រូវមានការរៀបចំស្តុក ក្នុងលក្ខណៈមួយ ដែលអាចធានានូវការគ្រប់គ្រងឱសថ បរិក្ខារពេទ្យ ប្រកបដោយប្រសិទ្ធភាព រួមមាន នីតិវិធីនៃការទទួល ការបង្វិលស្តុក (FEFO) ការត្រួតពិនិត្យ សារពើភ័ណ្ឌ និងរក្សាទុក កំណត់ត្រាឱ្យបានត្រឹមត្រូវ ព្រមទាំងធ្វើការចែកចាយទៅគ្រប់សេវាសុខាភិបាល ។
- បុគ្គលិកនៅសេវាសុខាភិបាលត្រូវទទួលការបណ្តុះបណ្តាលឱ្យបានទៀងទាត់ក្នុងការធ្វើ និងរក្សាកំណត់ត្រាឱ្យបានត្រឹមត្រូវត្រួតពិនិត្យ និងថែរក្សាស្តុកដោយអង្គភាពរបស់ក្រសួងសុខាភិបាលដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងឱសថ ។

### ២. ការគ្រប់គ្រងកាកសំណល់ផលិតផលសុខាភិបាល

#### ២.១. ការកាត់បន្ថយកាកសំណល់ផលិតផលសុខាភិបាល

កាកសំណល់នឹងត្រូវបានកាត់បន្ថយដោយ :

- ការធ្វើលទ្ធកម្មសមស្រប
- ការប្រកាន់ខ្ជាប់ទៅនឹងការអនុវត្តន៍ល្អក្នុងការចេញវេជ្ជបញ្ជា ដោយផ្អែកលើមគ្គុទ្ទេសក៍ព្យាបាល និងបញ្ជីឱសថសារវន្ត
- ការគ្រប់គ្រងស្តុកបានល្អ

- ការទប់ស្កាត់ការផ្តល់ជំនួយឱសថដែលមិនបានស្នើសុំ

**២.២. ការកំទេចចោលកាកសំណល់ផលិតផលសុខាភិបាលដែលផុតកំណត់ និងមិនអាចប្រើប្រាស់បាន**

- មគ្គុទ្ទេសក៍ត្រឹមត្រូវសម្រាប់ការកំទេចចោល ប្រកបដោយសុវត្ថិភាព នូវកាកសំណល់ផលិតផលសុខាភិបាលដែលផុតកំណត់ និងផលិតផលមិនអាចប្រើប្រាស់បាន ត្រូវមានការអនុម័តជាផ្លូវការ និងធ្វើការផ្សព្វផ្សាយ ។
- នៅពេលដែលកាកសំណល់ត្រូវតែចោលដោយមិនអាចចៀសវាងបាននោះ ត្រូវកំទេចវាក្នុងលក្ខណៈមួយដែលមានសុវត្ថិភាព និងមិនប៉ះពាល់ដល់បរិស្ថាន ដោយអនុលោមទៅតាមមគ្គុទ្ទេសក៍ជាតិស្តីពីការកំទេចចោលកាកសំណល់ ផលិតផលសុខាភិបាលដែលផុតកំណត់ និងផលិតផលមិនអាចប្រើប្រាស់បាន ។

## VIII. ការចែកចាយឱសថ

គោលនយោបាយនេះមានគោលបំណងធានានូវការចែកចាយឱសថ ឱ្យបានទាន់ពេលវេលា មានសុវត្ថិភាព និងប្រសិទ្ធភាព សម្រាប់អ្នកប្រើប្រាស់ដោយរក្សាគុណភាពឱសថតាមបណ្តាញផ្គត់ផ្គង់ និងអាចរកបានទៅពេលណាដែលត្រូវការ ។

**១. ការចែកចាយ និងការលក់ឱសថ**

មានតែឱសថដែលបានចុះទិដ្ឋាការ បញ្ជិកា ឬបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាលប៉ុណ្ណោះ ដែលអាចយកទៅចែកចាយ និង/ឬ លក់នៅព្រះរាជាណាចក្រកម្ពុជា ។

ការដឹកជញ្ជូនត្រឹមត្រូវ រួមមានការត្រួតពិនិត្យសីតុណ្ហភាព ការថែទាំ និងឧបករណ៍សម្រាប់ទំនាក់ទំនង និងបុគ្គលិកដែលចាំបាច់ក្នុងការរក្សាឱ្យបាននូវប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព នៃប្រព័ន្ធចែកចាយក្នុងវិស័យសាធារណៈ ជាពិសេសការដឹកជញ្ជូនឱសថទៅកាន់តំបន់ដាច់ស្រយាលនៅក្នុងប្រទេស ត្រូវមានការធានាដើម្បីសម្រួលដល់ការចែកចាយ ឱ្យបានទាន់ពេលវេលា មានសុវត្ថិភាព និងប្រសិទ្ធភាព ទៅកាន់គោលដៅត្រឹមត្រូវ ។

**១.១. ការចែកចាយឱសថនៅក្នុងវិស័យសាធារណៈ**

- ការចែកចាយឱសថនៅក្នុងវិស័យសាធារណៈ ត្រូវផ្អែកលើសំណើសុំផ្គត់ផ្គង់ពីសេវាសុខាភិបាល ។
- ការស្នើសុំឱសថពីសេវាសុខាភិបាល ត្រូវមានការរៀបចំដោយយោងកំណត់ត្រា និងឯកសារត្រឹមត្រូវហើយត្រូវផ្គត់ផ្គង់ឱសថទៅតាមកម្រិតនៃសេវាសុខាភិបាល ។
- ចំពោះសេវាសុខាភិបាលទើបបង្កើតថ្មី ដំបូងត្រូវផ្តល់នូវកញ្ចប់ឱសថ (Kit) ហើយធ្វើការផ្គត់ផ្គង់ជាបន្តបន្ទាប់ដោយ ផ្អែកទៅលើឯកសារដូចខាងលើ ។
- ចំពោះវិស័យសាធារណៈត្រូវផ្គត់ផ្គង់ឱសថដោយឥតគិតថ្លៃ សម្រាប់ប្រជាពលរដ្ឋកម្ពុជា ។

**១.២. ការចែកចាយ និងការលក់ឱសថនៅតាមវិស័យឯកជន**

- ត្រូវរៀបចំមគ្គុទ្ទេសក៍សម្រាប់ការនាំចូល និងការចែកចាយឱសថនៅតាមវិស័យឯកជន ។
- ឱសថសំរាប់វិស័យឯកជន ត្រូវចែកចាយទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ។
- ត្រូវរៀបចំ និងអនុវត្តគោលនយោបាយកំណត់តម្លៃ ។
- ឱសថគ្រប់ប្រភេទ មិនត្រូវចែកចាយដោយកន្លែងលក់ឱសថដែលគ្មានច្បាប់អនុញ្ញាត ។
- ការគ្រប់គ្រង និងការរៀបចំស្តុក ត្រូវមានលក្ខណៈធានាគុណភាពឱសថ ។
- ត្រូវរក្សាទុកនូវឯកសារស្តុកឱ្យបានត្រឹមត្រូវ ដើម្បីងាយស្រួលក្នុងការធ្វើសវនកម្ម ។

- មន្ត្រីដែលមានសិទ្ធិធ្វើអធិការកិច្ចឱសថ ត្រូវចុះធ្វើអធិការកិច្ចឱ្យបានទៀងទាត់នៅតាមទីតាំងវិស័យឯកជនហើយ បុគ្គលដែលត្រូវបានរកឃើញថា បានរំលោភបំពានច្បាប់ ត្រូវផ្តន្ទាទោសតាមច្បាប់ ។

## IX. ការធានាគុណភាពឱសថដែលកំពុងចរាចរ

គោលនយោបាយនេះមានគោលបំណង ធានាគុណភាពនៃការគ្រប់គ្រងឱសថគ្រប់ទិដ្ឋភាពទាំងអស់ ក្នុងវិស័យសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាថា ឱសថដែលបានទៅដល់ដៃអ្នកជំងឺ ជាឱសថដែលមានគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងឆ្លើយតបទៅតាមលក្ខណៈបច្ចេកទេស និងស្តង់ដារដែលបានកំណត់។ ប្រព័ន្ធធានាគុណភាព រួមមានការគ្រប់គ្រងបច្ចេកទេស និងច្បាប់។ ត្រូវមានការធានាគុណភាពឱសថចាប់ពី ដំណើរការនៃការជ្រើសរើស ការធ្វើលទ្ធកម្ម ការចែកចាយ រហូតដល់ការប្រើប្រាស់។

- គុណភាពឱសថដែលកំពុងចរាចរនៅក្នុងប្រព័ន្ធផ្គត់ផ្គង់សាធារណៈ និងឯកជន ត្រូវមានការត្រួតពិនិត្យឱ្យបានទៀងទាត់។
- មគ្គុទ្ទេសក៍តាមដានគុណភាពឱសថក្រោយពេលដាក់លក់នៅលើទីផ្សារ និងនីតិវិធីសម្រាប់ស្រង់ឱសថគំរូ ដើម្បីយកមកត្រួតពិនិត្យគុណភាព ត្រូវធ្វើការពិនិត្យសារឡើងវិញ និងអនុវត្តឱ្យបានល្អ ។
- ដើម្បីដោះស្រាយបញ្ហាឱសថអន់គុណភាព និងឱសថក្លែងក្លាយ ឱ្យមានប្រសិទ្ធភាព ត្រូវរៀបចំនីតិវិធី រួមមាន ការដាក់ពិន័យតាមច្បាប់ជាធរមាន។

## X. ការប្រើប្រាស់ឱសថសមស្រប

គោលនយោបាយនេះមានគោលបំណងធានាថាឱសថដែលត្រូវចេញវេជ្ជបញ្ជាឱ្យប្រើ និងចែកចាយដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងមានការប្រើប្រាស់ឱ្យបានសមស្រប ដើម្បីផ្តល់អត្ថប្រយោជន៍ជាអតិបរមាក្នុងការព្យាបាលដល់អ្នកជំងឺ និងកាត់បន្ថយការបាត់បង់ ការខ្ជះខ្ជាយ គ្រោះថ្នាក់ដែលកើតឡើង ដោយការប្រើប្រាស់ឱសថមិនបានសមស្រប ។

### ១. ការអប់រំ និងការបណ្តុះបណ្តាល

- ត្រូវធានាឱ្យមានការអប់រំ និងការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល រួមទាំងបុគ្គលិកបម្រើការនៅតាមឱសថស្ថាន និងគិលានុបដ្ឋាកទៅតាមកម្មវិធីសិក្សាដែលបានរៀបចំ ។
- ត្រូវពង្រឹងវគ្គសិក្សាឡើងវិញ និងអប់រំបន្ត ដើម្បីបង្កើនចំណេះដឹងថែមទៀតឱ្យបានត្រឹមត្រូវ ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ ។
- ត្រូវផ្តល់ការបណ្តុះបណ្តាលសម្រាប់ករណីពិសេស ដល់បុគ្គលិកសុខាភិបាលដែលបានជ្រើសរើស ឧទាហរណ៍ ក្នុងករណីការប្រើប្រាស់ឱសថសម្រាប់ជំងឺគ្រុនចាញ់ របេង និងអេដស៍ ។ល។
- ត្រូវមានការបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាលអំពីការផ្តល់ប្រឹក្សា ដើម្បីពួកគាត់អាចជួយឱ្យអ្នកជំងឺយល់ច្បាស់អំពីការប្រើប្រាស់ឱសថ ក៏ដូចជាការថែរក្សា និងទុកដាក់ឱសថទាំងនោះឱ្យបានត្រឹមត្រូវ ដើម្បីចៀសវាងការខូចខាត និងការខ្ជះខ្ជាយ ។

### ២. ការចេញវេជ្ជបញ្ជា

- វិសាលភាពក្នុងការចេញវេជ្ជបញ្ជា ត្រូវកំណត់តាមកម្រិតជំនាញដែលបានអនុញ្ញាត ។

- អ្នកចេញវេជ្ជបញ្ជានៅគ្រប់វិស័យរួមមាន វិស័យសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវចេញវេជ្ជបញ្ជាចំពោះតែឱសថណាដែលស្ថិតក្នុងបញ្ជីកំណត់ ទៅតាមកម្រិតជំនាញរបស់អ្នកចេញវេជ្ជបញ្ជា និងយោងទៅតាមសេចក្ដីណែនាំរបស់ក្រសួងសុខាភិបាល ។
- អង្គភាពក្រោមក្រសួងសុខាភិបាល ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងឱសថ ត្រូវប្រឹងប្រែងត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួន និងវាយតម្លៃលើការចេញវេជ្ជបញ្ជា ហើយត្រូវសហការជាមួយផ្នែកផ្សេងៗ នៃអង្គភាពគ្រប់គ្រងឱសថ ដើម្បីធានាឱ្យមានការចេញវេជ្ជបញ្ជាត្រឹមត្រូវ និងមានចំណាយសមស្រប ។

### ៣. ការចែកចាយឱសថ

- មគ្គុទ្ទេសក៍ស្ដីពីការចែកចាយឱសថ ដែលជាផ្នែកមួយនៃគោលការណ៍អនុវត្តន៍ល្អក្នុងឱសថស្ថាន (GPP) ត្រូវពង្រឹង ហើយការប្រើប្រាស់មគ្គុទ្ទេសក៍ត្រូវមានរយៈពេលកំណត់ ក្នុងការពិនិត្យឡើងវិញ ។
- ឱសថត្រូវចែកចាយប្រកបដោយប្រសិទ្ធភាព និងត្រឹមត្រូវនៅក្នុងវិស័យសាធារណៈ ដោយយោងតាមបញ្ជីឱសថសារវន្ត និងស្របតាមគោលនយោបាយស្ដីពីឱសថ និងបទប្បញ្ញត្តិក្នុងឱសថស្ថាន រួមមានសេចក្ដីណែនាំសម្រាប់ការវេចខ្ចប់ និងការបិទស្លាកសញ្ញា ។ គោលការណ៍ដូចគ្នានេះត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ក្នុងវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ។
- គ្រប់វិស័យទាំងអស់ ឱសថត្រូវចែកចាយដោយ បុគ្គលិកដែលទទួលបានការអនុញ្ញាតតែប៉ុណ្ណោះ ។
- ឱសថស្ថានគ្រប់កម្រិតទាំងអស់ត្រូវលក់ឱសថដែលមានវេជ្ជបញ្ជាតែប៉ុណ្ណោះ លើកលែងតែឱសថដែលអាចទិញបានដោយមិនចាំបាច់មានវេជ្ជបញ្ជាដូចដែលក្រសួងសុខាភិបាលបានកំណត់ ។
- មន្ត្រីអធិការកិច្ចមានសមត្ថកិច្ចត្រូវធ្វើអធិការកិច្ចឱ្យបានទៀងទាត់ នៅទីតាំងដែលមានការចែកចាយឱសថ ដើម្បីធានាថារាល់បទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងការចែកចាយឱសថ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ។

### ៤. ព័ត៌មានឱសថ

- ត្រូវឱ្យមានភាពងាយស្រួល ដើម្បីឱ្យបុគ្គលិកសុខាភិបាលទាំងអស់អាចរកបាននូវព័ត៌មានឱសថ ដែលគួរឱ្យទុកចិត្ត មានលក្ខណៈវិទ្យាសាស្ត្រ និងឯករាជ្យ ក្នុងការចេញវេជ្ជបញ្ជា និងការចែកចាយឱសថ ឱ្យបានសមស្រប រួមមានមគ្គុទ្ទេសក៍ព្យាបាល បញ្ជីឱសថសារវន្ត និងឯកសារយោងដទៃទៀត ។
- ព័ត៌មាន និងទិន្នន័យឱសថដែលមានប្រយោជន៍ ការប្រើប្រាស់ឱសថ និងការអនុវត្តន៍ក្នុងឱសថស្ថាន ត្រូវបានប្រមូលដើម្បីកំណត់គោលដៅសម្រាប់ការអប់រំ ឬការពិនិត្យឡើងវិញនូវគោលការណ៍អនុវត្តល្អក្នុងឱសថស្ថាន តាមការចាំបាច់ ។

#### ៤.១. ការយល់ដឹងរបស់សហគមន៍អំពីឱសថ និងការប្រើប្រាស់ឱសថដោយខ្លួនឯង

- ត្រូវផ្ដល់ព័ត៌មានអំពីការប្រើប្រាស់ឱសថ និងការព្យាបាលដល់សាធារណៈជនដោយគ្មានការលំអៀងទៅតាមភាពជាក់ស្ដែង ។
- ត្រូវមានវគ្គបណ្ដុះបណ្ដាលសមស្របទៅតាមសហគមន៍ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីឱសថនិងការប្រើប្រាស់របស់វាដោយខ្លួនឯង ។

#### ៤.២. ការតាមដានពីផលវិបាករបស់ឱសថ

- ត្រូវពង្រឹងប្រព័ន្ធតាមដានពីផលរំខានរបស់ឱសថ និងដាក់បញ្ចូលនូវនីតិវិធី ក្នុងការរាយការណ៍អំពីផលរំខានរបស់វា ។ ត្រូវកែលំអប្រព័ន្ធនេះដើម្បីឈានទៅដល់ស្តង់ដារអន្តរជាតិ ។
- ត្រូវលើកទឹកចិត្តបុគ្គលិកសុខាភិបាល និងសមាជិកសហគមន៍ឱ្យរាយការណ៍អំពីផលរំខានរបស់ឱសថ ដល់មណ្ឌលព័ត៌មានឱសថដែលនៅជិតបំផុត ។

## XI. ឱសថបុរាណ

គោលនយោបាយនេះមានគោលបំណងទទួលស្គាល់ គោលនយោបាយឱសថបុរាណរបស់កម្ពុជា ដោយរួមបញ្ចូលការប្រើប្រាស់ឱសថបុរាណទៅក្នុងប្រព័ន្ធថែទាំសុខភាពបឋម ។

ត្រូវអនុវត្តគោលនយោបាយឱសថបុរាណជាថ់ដោយឡែក ដែលមានបំណងដាក់បញ្ចូលវា ទៅក្នុងផ្នែកមួយនៃសេវាប្រើប្រាស់ឱសថ ទៅតាមគោលការណ៍ណែនាំសម្រាប់ការថែទាំសុខភាពបឋម ។

## XII. ការផ្សព្វផ្សាយពាណិជ្ជកម្ម និងការលើកកម្ពស់ការយល់ដឹង

គោលនយោបាយនេះមានគោលបំណងធានាថា ការផ្សាយពាណិជ្ជកម្ម និងការលើកកម្ពស់យល់ដឹងអំពីឱសថ ត្រូវបានធ្វើឡើង ដោយមានស្តង់ដារវិជ្ជាជីវៈខ្ពស់ និងគោរពតាមល័ក្ខខ័ណ្ឌតម្រូវនៃបទដ្ឋានច្បាប់ និងនិយ័តកម្មឱសថ ។

- ត្រូវរៀបចំ និងធ្វើការចែកចាយមគ្គុទ្ទេសក៍ សម្រាប់លើកកម្ពស់ការយល់ដឹងអំពីឱសថ រួមមានលក្ខណៈវិនិច្ឆ័យត្រឹមត្រូវតាមក្រមសីលធម៌ ដល់ភាគីដែលពាក់ព័ន្ធ ។
- សកម្មភាពលើកកម្ពស់ការយល់ដឹងអំពីឱសថ ត្រូវស្របគ្នាជាមួយនឹងគោលបំណងនៃគោលនយោបាយស្តីពីឱសថ ។
- ត្រូវបន្តហាមឃាត់នូវការផ្សព្វផ្សាយដោយផ្ទាល់ទៅដល់អ្នកប្រើប្រាស់ អំពីឱសថដែលត្រូវទិញដោយមានវេជ្ជបញ្ជា ។
- ការផ្សាយពាណិជ្ជកម្មដែលមានគោលបំណង ឬពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឱសថមិនត្រឹមត្រូវសម្រាប់កុមារ ត្រូវចាត់ទុកជាការខុសច្បាប់ ។
- ការផ្សាយពាណិជ្ជកម្មឱសថ និងសកម្មភាពផ្សព្វផ្សាយ ត្រូវមានការត្រួតពិនិត្យដោយប្រុងប្រយ័ត្ន ដើម្បីធានាថាពួកគេអនុលោមតាមលក្ខណៈវិនិច្ឆ័យត្រឹមត្រូវតាមក្រមសីលធម៌ ។
- ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍នៃការផ្សាយពាណិជ្ជកម្មឱសថ ( ស្លាកសញ្ញាក្រុមហ៊ុន ការគាំទ្រសកម្មភាព ។ល ។) មិនត្រូវពាក់ព័ន្ធជាមួយនឹងកម្មវិធីជាតិណាមួយរបស់ក្រសួងសុខាភិបាលឡើយ ។

## XIII. កិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយប្រទេសនានា និងទីភ្នាក់ងារអន្តរជាតិ

គោលនយោបាយនេះមានគោលបំណងបន្តសហប្រតិបត្តិការបច្ចេកទេស យ៉ាងសកម្មលើគ្រប់វិស័យដែលទាក់ទងនឹងបញ្ហាឱសថ ដើម្បីបង្កើនការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពតាមកម្រិតធនធានដែលមានស្រាប់ ក្នុងការអនុវត្តន៍គោលនយោបាយស្តីពីឱសថ ។

### ១. កិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ

រាល់ខ្លឹមសារនៃគោលនយោបាយស្តីពីឱសថ នីតិវិធីក្នុងការចុះទិដ្ឋាការ បញ្ជីកាឱសថ និងការរៀបចំមគ្គុទ្ទេសក៍ព្យាបាល ត្រូវឱ្យស្របជាមួយនឹងប្រទេសនានា ដើម្បីធ្វើឱ្យមានការងាយស្រួលក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងក្នុងតំបន់ព្រមទាំង

ទទួលបានអត្ថប្រយោជន៍ពីការចែករំលែកបទពិសោធន៍ និងនីតិវិធីរួមគ្នា ។ ត្រូវលើកទឹកចិត្ត និងស្វែងរកឱកាសបណ្តុះបណ្តាលនៅក្នុងតំបន់ លើគ្រប់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងឱសថ និងការអនុវត្តន៍ ។

**២. កិច្ចសហប្រតិបត្តិការបច្ចេកទេស និងការចែករំលែកព័ត៌មាន**

កិច្ចសហប្រតិបត្តិការបច្ចេកទេស និងការចែករំលែកព័ត៌មាន លើគ្រប់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងឱសថ ត្រូវមានការលើកទឹកចិត្ត និងមានការគាំទ្រទៅតាមវិស័យផ្សេងៗ រួមមាន ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ ឧទាហរណ៍:

- ការធ្វើឱ្យប្រសើរឡើង និងរក្សាដំណើការផ្នែក ឬអង្គភាពដែលទទួលបន្ទុកការប្រាស្រ័យទាក់ទង
- ការផ្ទេរបច្ចេកវិទ្យាសមស្រប
- ការពង្រឹងគណៈកម្មការព្យាបាលរោគ
- ការប្រើប្រាស់វិធីសាស្ត្ររួមក្នុងការគ្រប់គ្រងជំងឺ តាមរយៈមគ្គុទ្ទេសក៍ព្យាបាល
- ការវាយតម្លៃឱសថ
- ការផ្លាស់ប្តូរព័ត៌មានអំពីគ្រឹះស្ថានផ្គត់ផ្គង់ឱសថ
- ការធានាគុណភាព និងកិច្ចសហការជាមួយមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពក្នុងតំបន់ និងមន្ទីពិសោធន៍ដទៃទៀត ។

## XIV. ការត្រួតពិនិត្យ និងការវាយតម្លៃ

គោលនយោបាយនេះមានគោលបំណងធានាឱ្យមានការអនុវត្តន៍ប្រកបដោយជោគជ័យនូវគ្រប់ទិដ្ឋភាពទាំងអស់នៃគោលនយោបាយស្តីពីឱសថ តាមរយៈការបង្កើតយន្តការសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ការងារ ។

១. ផែនការយុទ្ធសាស្ត្រវិស័យឱសថ ឆ្នាំ ២០០៥-២០១០ និង "គោលការណ៍អនុវត្តល្អក្នុងឱសថស្ថាននៃប្រទេសកម្ពុជា" ត្រូវមានការត្រួតពិនិត្យឡើងវិញ និងទុកជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍គោលនយោបាយស្តីពីឱសថ ។

២. ត្រូវកំណត់សូចនាករសម្រាប់វាស់វឌ្ឍនភាព ឆ្ពោះទៅរកការសម្រេចបាននូវទិសដៅនៃគោលនយោបាយ នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ។

៣. ប្រតិបត្តិការស្រាវជ្រាវលើគ្រប់ទិដ្ឋភាពទាំងអស់នៃគោលនយោបាយស្តីពីឱសថ គឺជាឧបករណ៍សំខាន់មួយសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃ ។

**KINGDOM OF CAMBODIA**

**NATION RELIGION KING**

*Ministry of Health*

# *Medicines Policy*

# *of*

# *The Kingdom of Cambodia*

August 2010

*Supported by WHO*

# Medicines Policy 2010

## Contents

I. INTRODUCTION ..... 3
Vision ..... 4
Mission ..... 4
Key objectives ..... 4
Approaches ..... 4
II. LEGAL FRAMEWORK ..... 5
1. Legislation and Regulation ..... 5
*1.1 Legislation* ..... 5
*1.2 Intellectual Property Rights related to Pharmaceuticals* ..... 5
2. The role of the national medicines regulatory authority ..... 5
3. Regulatory Affairs, Quality Assurance and Licensing ..... 6
*3.1. National Laboratory for Medicines Quality Control* ..... 6
III. HUMAN RESOURCES ..... 6
IV. FINANCIAL RESOURCES ..... 7
V. SELECTION ..... 7
1. Treatment guidelines and Essential Medicines List ..... 7
*1.1 National Therapeutic Committee* ..... 7
*1.2. Standard Treatment Guidelines and the selection of medicines* ..... 7
2. Use of medicines in expatriate medical teams and vertical programs ..... 7
VI. PROCUREMENT ..... 8
1. General principles on the purchase of medicines and medical supplies for the public sector ..... 8
*1.1 Local production* ..... 8
*1.2 Donations* ..... 8
2. Procurement by Cambodian private sector ..... 8
VII. STORAGE FACILITIES AND SYSTEMS ..... 9
1. Stock management ..... 9
2. Waste management ..... 9
*2.1 Waste minimization* ..... 9
*2.2 Disposal of expired and other unusable health products waste* ..... 10
VIII. DISTRIBUTION ..... 10
1. Distribution and sale of medicines ..... 10
*1.1 Distribution of medicines in the public sector* ..... 10
*1.2 Distribution and sales of medicines in the private sector* ..... 10
IX. QUALITY ASSURANCE OF MEDICINES IN CIRCULATION ..... 11
X. RATIONAL MEDICINES USE ..... 11
1. Education and Training ..... 11
2. Prescribing ..... 11
3. Dispensing ..... 11
4. Medicines Information ..... 12
*4.1 Community understanding about all medicines and self-medication* ..... 12
*4.2 Pharmacovigilance* ..... 12
XI. TRADITIONAL MEDICINES ..... 12
